ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
លេខ:......០០៩.........គ.ល.ក.ប្រក

# ប្រកាស
# ស្តីពី
# ការគ្រប់គ្រងលើវិធានល្បែង ឧបករណ៍និង/ឬកម្មវិធីល្បែង សម្រាប់ប្រតិបត្តិការកាស៊ីណូ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣១ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៦៥អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា
- បានឃើញប្រកាសលេខ ០០២គ.ល.ក.ប្រក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២១ ស្តីពីនីតិវិធី បែបបទ និងលក្ខខណ្ឌនៃការផ្តល់ ការផ្ទេរ និងការបន្តសុពលភាពអាជ្ញាបណ្ណកាស៊ីណូ និងអាជ្ញាបណ្ណល្បែងផ្សងសំណាង
- យោងតាមការសម្រេចរបស់គណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា នាសម័យប្រជុំលើកទី៣ អាណត្តិទី១ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១


អាសយដ្ឋាន : លេខ ៦-៨ មហាវិថីព្រះនរោត្តម, រាជធានីភ្នំពេញ កម្ពុជា
Address: No 6-8 Preah Norodom Blvd, Phnom Penh, Cambodia.
ទូរសព្ទ: (+៨៥៥)២៣ ៩០២ ០៩០
Phone: (+855)23 902 090

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះកំណត់អំពីវិធានល្បែង ឧបករណ៍ និង/ឬកម្មវិធីល្បែងសម្រាប់ប្រតិបត្តិការកាស៊ីណូ ដើម្បីធានាដល់ដំណើរការលេងល្បែងប្រកបដោយទំនុកចិត្ត សុចរិតភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងរក្សាបាននូវសន្តិសុខនិងសណ្តាប់ធ្នាប់ក្នុងវិស័យល្បែងពាណិជ្ជកម្ម។

**ប្រការ២ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការកាស៊ីណូនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ការគ្រប់គ្រងលើប្រភេទល្បែង វិធានល្បែង ឧបករណ៍និង/ឬកម្មវិធីល្បែង

### ផ្នែកទី១
### ប្រភេទល្បែង

**ប្រការ៣ ._**

ប្រភេទល្បែងណាមួយដែលអាចដាក់ដំណើរការ ឬលេងនៅក្នុងកាស៊ីណូបានលុះត្រាតែប្រភេទល្បែងនោះត្រូវបាន៖

- យល់ព្រមជាមុនពី គ.ល.ក. ដែលការយល់ព្រមនេះនៅមានសុពលភាពជាធរមាន
- ដំណើរការឬលេងស្របតាមរបៀបលេងនិងវិធានល្បែងដែលអនុម័តដោយ គ.ល.ក. និង
- ដំណើរការដោយបុគ្គលិកពិសេសដែលមានអាជ្ញាបណ្ណពី គ.ល.ក.។

**ប្រការ៤ ._**

ប្រតិបត្តិករកាស៊ីណូត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើសុំចុះបញ្ជីប្រភេទល្បែងសម្រាប់ដំណើរការក្នុងកាស៊ីណូមកអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដោយភ្ជាប់នូវឯកសារដូចខាងក្រោម៖

- ពាក្យស្នើសុំចុះបញ្ជីប្រភេទល្បែង
- តារាងប្រភេទល្បែង និងយថាប្រភេទនៃប្រភេទល្បែងនីមួយៗ
- កម្រៃទម្រង់ការ
- កម្រៃសម្រាប់ចំណាយរបស់ គ.ល.ក. ក្នុងការសិក្សា ស្រាវជ្រាវ និងស៊ើបអង្កេត។

ទម្រង់នៃពាក្យស្នើសុំចុះបញ្ជីប្រភេទល្បែងត្រូវកំណត់ដោយអគ្គលេខាធិការដ្ឋាននៃ គ.ល.ក.។

**ប្រការ៥ ._**

អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវធ្វើការសិក្សា ស្រាវជ្រាវ និងពិចារណាលើពាក្យស្នើសុំដើម្បីបញ្ជាក់ពីភាពសមស្របសម្រាប់ការប្រើប្រាស់នៅក្នុងកាស៊ីណូ និងអាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ឯកសារពាក់ព័ន្ធបន្ថែម ឬបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់។

អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចយល់ព្រម ឬបដិសេធលើពាក្យស្នើសុំ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ៦ ..**

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីប្រភេទល្បែង ត្រូវបង់កម្រៃ ជូន គ.ល.ក. ដូចខាងក្រោម៖

១. កម្រៃទម្រង់ការចំនួន ២.០០០.០០០ (ពីរលាន) រៀល

២. កម្រៃសម្រាប់ចំណាយរបស់ គ.ល.ក. ក្នុងការសិក្សា ស្រាវជ្រាវ និងស៊ើបអង្កេត ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល

៣. កម្រៃចុះបញ្ជីប្រភេទល្បែង ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ក្នុងមួយប្រភេទល្បែង។

កម្រៃខាងលើត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក. បន្ទាប់ពីទទួលបានប័ណ្ណបង់ប្រាក់។

**ប្រការ៧ ..**

គ.ល.ក. អាចផ្តល់ការអនុម័តផ្សេងៗគ្នាទៅលើប្រភេទល្បែង អាស្រ័យតាមការស្នើសុំរបស់ប្រតិបត្តិករ ភាពខុសគ្នានៃពេលវេលា ទីកន្លែង និងកាលៈទេសៈ។

ប្រភេទល្បែង អាចត្រូវបានលុបចេញពីបញ្ជីប្រភេទល្បែងតាមការស្នើសុំរបស់ប្រតិបត្តិករ ដោយមានការត្រួតពិនិត្យពីមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដើម្បីដាក់ជូនប្រធាន គ.ល.ក. ពិនិត្យ និងសម្រេច។

## ផ្នែកទី២
## វិធានល្បែង

**ប្រការ៨ ..**

វិធានល្បែងណាមួយដែលដាក់ឱ្យដំណើរការ ឬលេងនៅក្នុងកាស៊ីណូបានលុះត្រាតែវិធានល្បែងនោះទទួលបានការអនុញ្ញាតជាមុនពី គ.ល.ក.។

**ប្រការ៩ ..**

ប្រតិបត្តិករកាស៊ីណូត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើសុំចុះបញ្ជីវិធានល្បែងសម្រាប់ដំណើរការក្នុងកាស៊ីណូមកអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដោយភ្ជាប់នូវឯកសារដូចខាងក្រោម៖

- ពាក្យស្នើសុំចុះបញ្ជីវិធានល្បែង
- តារាងវិធានល្បែង និងការពិពណ៌នាអំពីវិធានល្បែងនីមួយៗ
- កម្រៃទម្រង់ការ
- កម្រៃសម្រាប់ចំណាយរបស់ គ.ល.ក. ក្នុងការសិក្សា ស្រាវជ្រាវ និងស៊ើបអង្កេត។

ទម្រង់នៃពាក្យស្នើសុំចុះបញ្ជីវិធានល្បែងត្រូវកំណត់ដោយអគ្គលេខាធិការដ្ឋាននៃ គ.ល.ក.។

**ប្រការ១០ ..**

អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវធ្វើការសិក្សា ស្រាវជ្រាវ និងពិចារណាលើពាក្យស្នើសុំដើម្បីបញ្ជាក់ពីភាពសមស្របសម្រាប់ការប្រើប្រាស់នៅក្នុងកាស៊ីណូ និងអាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់ឯកសារពាក់ព័ន្ធបន្ថែម ឬបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់។

អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចយល់ព្រម ឬបដិសេធលើពាក្យស្នើសុំ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការដ្ឋាន នៃ គ.ល.ក. ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ១១ ៈ**

អ្នកដាក់ពាក្យស្នើសុំចុះបញ្ជីវិធានល្បែង ត្រូវបង់កម្រៃ ជូន គ.ល.ក. ដូចខាងក្រោម៖

១. កម្រៃទម្រង់ការចំនួន ២.០០០.០០០ (ពីរលាន) រៀល

២. កម្រៃសម្រាប់ចំណាយរបស់ គ.ល.ក. ក្នុងការសិក្សា ស្រាវជ្រាវ និងស៊ើបអង្កេត ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល

៣. កម្រៃចុះបញ្ជីវិធានល្បែង ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល ក្នុងមួយវិធានល្បែង។

កម្រៃខាងលើត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក. បន្ទាប់ពីទទួលបានប័ណ្ណបង់ប្រាក់។

**ប្រការ១២ ៈ**

គ.ល.ក. អាចផ្តល់ការអនុម័តផ្សេងៗគ្នាទៅលើវិធានល្បែង អាស្រ័យតាមការស្នើសុំរបស់ប្រតិបត្តិករ ភាពខុសគ្នានៃពេលវេលា ទីកន្លែង និងកាលៈទេសៈ។

វិធានល្បែង អាចត្រូវបានលុបចេញពីបញ្ជីវិធានល្បែងតាមការស្នើសុំរបស់ប្រតិបត្តិករ ដោយមានការត្រួតពិនិត្យពីមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដើម្បីដាក់ជូនប្រធាន គ.ល.ក. ពិនិត្យ និងសម្រេច។

**ប្រការ១៣ ៈ**

វិធានល្បែងដែលទទួលបានការអនុញ្ញាតឱ្យដំណើរការក្នុងកាស៊ីណូ ត្រូវដាក់បង្ហាញក្នុងទីតាំងកាស៊ីណូ ឬនៅតុល្បែង ឬណែនាំ ឬផ្តល់ជំនួយបច្ចេកទេសដល់ភ្ញៀវល្បែង។

រាល់ការកែប្រែវិធានល្បែង ប្រតិបត្តិករត្រូវស្នើសុំការអនុញ្ញាតជាមុនពី គ.ល.ក. ទៅតាមទម្រង់ដែលកំណត់ដោយអគ្គលេខាធិការដ្ឋាននៃ គ.ល.ក.។

## ផ្នែកទី៣
## ការគ្រប់គ្រងលើឧបករណ៍និង/ឬកម្មវិធីល្បែង

**ប្រការ១៤ ៈ**

ឧបករណ៍និង/ឬកម្មវិធីល្បែងដែលអាចស្នើសុំចុះបញ្ជី និងអាចដាក់ឱ្យដំណើរការនៅក្នុងកាស៊ីណូបាន លុះត្រាតែ ការផលិត ការដំឡើង ការនាំចូល ការលក់ ឬចែកចាយដោយក្រុមហ៊ុនដែលមានអាជ្ញាបណ្ណពី គ.ល.ក.។

ឧបករណ៍និង/ឬកម្មវិធីល្បែងដែលអាចចុះបញ្ជី និងដំណើរការនៅក្នុងកាស៊ីណូបានលុះត្រាតែឧបករណ៍ និង/ឬកម្មវិធីល្បែងនោះ មានអាយុកាលមិនលើសពី ១០ (ដប់) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការផលិត។

**ប្រការ១៥ ៈ**

ប្រតិបត្តិករកាស៊ីណូ ត្រូវបំពេញបែបបទ និងដាក់ពាក្យស្នើសុំចុះបញ្ជីឧបករណ៍និង/ឬកម្មវិធីល្បែងមក គ.ល.ក. ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារតម្រូវ ដូចខាងក្រោម៖

១. អាជ្ញាបណ្ណកាស៊ីណូដែលមានសុពលភាព ថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ

២. ព័ត៌មានអំពីឧបករណ៍និង/ឬកម្មវិធីល្បែងដែលត្រូវស្នើសុំ មានជាអាទិ៍ ឈ្មោះ លេខសម្គាល់ ម៉ូដែល ឈ្មោះក្រុមហ៊ុនផលិត ឈ្មោះក្រុមហ៊ុននាំចូល/ផ្គត់ផ្គង់ ថ្ងៃខែឆ្នាំផលិត និងរូបភាពពណ៌នាអំពីឧបករណ៍ល្បែង (cabinet specification)

៣. ព័ត៌មានអំពីប្រព័ន្ធប្រតិបត្តិការ (operating system) និង/ឬកម្មវិធីល្បែង (game software)

៤. ឯកសារណែនាំពីឧបករណ៍ល្បែងនិង/ឬកម្មវិធីល្បែង (game manual)

៥. ឯកសារកំណត់ពីរបៀបលេង និងវិធានល្បែង (how to play and game rule) ស្របតាមស្តង់ដាបច្ចេកទេស
៦. ឯកសារបញ្ជាក់ពីការកំណត់អត្រាភ្នៀវឈ្នះ (return to played percentage - RTP) ពីក្រុមហ៊ុនផលិត ដំឡើង នាំចូល លក់ ឬចែកចាយ។ ត្រូវបានលើកលែងចំពោះម៉ាស៊ីនល្បែងដែលមានលក្ខណៈពាក់កណ្ដាលមេកានិកឬអេឡិចត្រូនិក (semi-automated electronic table game)
៧. ឯកសារបញ្ជាក់ពីការកំណត់អំពីទឹកប្រាក់ភ្នាល់តិចបំផុត (min bet) និងច្រើនបំផុត(max bet)
៨. អនុលោមភាពជាមួយនឹងស្តង់ដាបច្ចេកទេស និងលក្ខខណ្ឌតម្រូវផ្សេងទៀត
៩. ឯកសារបញ្ជាក់ពីការត្រួតពិនិត្យលក្ខណៈបច្ចេកទេសឧបករណ៍និង/ឬកម្មវិធីល្បែង
១០. គំរូរបាយការណ៍គណនេយ្យបោះពុម្ពដោយឧបករណ៍ល្បែង
១១. វិក្កយបត្របង់កម្រៃទម្រង់ការ
១២. វិក្កយបត្របង់កម្រៃសម្រាប់ចំណាយរបស់ គ.ល.ក. ក្នុងការសិក្សា ស្រាវជ្រាវ និងស៊ើបអង្កេត។

**ប្រការ១៦ .-**

បន្ទាប់ពីទទួលបានពាក្យស្នើសុំ អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវធ្វើការសិក្សា ស្រាវជ្រាវ និងពិចារណាលើពាក្យស្នើសុំ និងអាចតម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំផ្តល់នូវព័ត៌មាន ឬឯកសារពាក់ព័ន្ធបន្ថែមតាមការចាំបាច់។

អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរអំពីសេចក្តីសម្រេចយល់ព្រម ឬបដិសេធលើពាក្យស្នើសុំ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ១៧ .-**

ប្រតិបត្តិករដែលដាក់ពាក្យស្នើសុំ ត្រូវបង់កម្រៃ ជូន គ.ល.ក. ដូចខាងក្រោម៖

១. កម្រៃទម្រង់ការសម្រាប់ការស្នើសុំចុះបញ្ជីឧបករណ៍និង/ឬកម្មវិធីល្បែង និងការស្នើសុំលុបចេញពីបញ្ជី និងការកម្ទេចឧបករណ៍និង/ឬកម្មវិធីល្បែងចាស់ៗ ចំនួន ២.០០០.០០០ (ពីរលាន) រៀល
២. កម្រៃសម្រាប់ចំណាយរបស់ គ.ល.ក. ក្នុងការសិក្សា ស្រាវជ្រាវ និងស៊ើបអង្កេត ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល
៣. កម្រៃចុះបញ្ជីឧបករណ៍និង/ឬកម្មវិធីល្បែងប្រចាំឆ្នាំ៖
   - ចំនួន ៤០០.០០០ (បួនរយពាន់) រៀល ក្នុងមួយម៉ាស៊ីនល្បែង (ស្លតម៉ាស៊ីន)
   - ចំនួន ២.០០០.០០០ (ពីរលាន) រៀល ក្នុងមួយម៉ាស៊ីនល្បែងសម្រាប់អ្នកលេងពី ២-៨ នាក់/កន្លែង។ ករណីម៉ាស៊ីនល្បែងសម្រាប់អ្នកលេងលើសពី ៨ នាក់/កន្លែង (8 stations) ត្រូវបង់ចំនួន ៣០០.០០០ (បីរយពាន់) រៀល ក្នុង ១ នាក់/កន្លែង (1 station)
   - ចំនួន ២.០០០.០០០ (ពីរលាន) រៀល ក្នុងមួយតុល្បែង។

កម្រៃខាងលើត្រូវបង់ចូលទៅក្នុងគណនីរបស់ គ.ល.ក. បន្ទាប់ពីទទួលបានប័ណ្ណបង់ប្រាក់។

**ប្រការ១៨ .-**

ឧបករណ៍និង/ឬកម្មវិធីល្បែង អាចត្រូវបានលុបចេញពីបញ្ជីឧបករណ៍និង/ឬកម្មវិធីល្បែងតាមការស្នើសុំរបស់ប្រតិបត្តិករ ដោយមានការត្រួតពិនិត្យពីមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ដើម្បីដាក់ជូនប្រធាន គ.ល.ក. ពិនិត្យ និងសម្រេច។

**ប្រការ១៩ .-**

ប្រតិបត្តិករកាស៊ីណូ ត្រូវមានកាតព្វកិច្ចផ្សេងទៀត ដូចខាងក្រោម៖

- បិតភ្ជាប់លតាបត្រត្រួតពិនិត្យលើម៉ាស៊ីនល្បែងឬតុល្បែងនោះ ដើម្បីបង្ហាញដល់ភ្ញៀវល្បែង និងអ្នកពាក់ព័ន្ធ
- ថែទាំត្រាសុវត្ថិភាព (seal) របស់ឧបករណ៍និង/ឬកម្មវិធីល្បែងមិនឱ្យខូចខាត ឬខុសទ្រង់ទ្រាយដើម
- ផ្ដល់របាយការណ៍មកអគ្គលេខាធិការដ្ឋាននៃ គ.ល.ក. ឱ្យបានទាន់ពេលវេលាក្នុងករណីមានឧបករណ៍និង/ឬកម្មវិធីល្បែងណាមួយដំណើរការខុសប្រក្រតី ឬមិនដំណើរការ។

**ប្រការ២០ .-**

ប្រភេទ និងចំនួននៃឧបករណ៍និង/ឬកម្មវិធីល្បែង ដែលត្រូវកម្ទេចចោល ត្រូវមានការអនុញ្ញាតជាមុនពី គ.ល.ក.។

## ជំពូកទី៣

## ការសាកល្បង ឬការធ្វើតេស្តឧបករណ៍និង/ឬកម្មវិធីល្បែង

**ប្រការ២១ .-**

ប្រតិបត្តិករកាស៊ីណូអាចដំណើរការល្បែងសាកល្បងសម្រាប់ហ្វឹកហាត់និងណែនាំដល់បុគ្គលិក ឬធ្វើតេស្តឧបករណ៍និង/ឬកម្មវិធីល្បែងបាន លុះត្រាតែមានការឯកភាពជាមុនពី គ.ល.ក.។

លក្ខខណ្ឌសម្រាប់ការសាកល្បង ឬការធ្វើតេស្តឧបករណ៍និង/ឬកម្មវិធីល្បែង មានដូចខាងក្រោម៖

- សម្រាប់តែគោលបំណងបណ្ដុះបណ្ដាលបុគ្គលិក ការសាកល្បង ឬការធ្វើតេស្តឧបករណ៍ល្បែង ឬដំណើរការល្បែង ការបង្ហាញពីវិធាននិងរបៀបលេង
- មិនប្រើសាច់ប្រាក់ ឬប័ណ្ណទូទាត់ប្រាក់ក្នុងការសាកល្បង ឬការធ្វើតេស្ត
- មិនទទួលបានប្រាក់ឈ្នះ ឬរង្វាន់ផ្សេងៗពីការសាកល្បង ឬការធ្វើតេស្ត។

## ជំពូកទី៤

## ទណ្ឌកម្ម

**ប្រការ២២ .-**

បុគ្គលណាដែលដាក់ដំណើរការប្រភេទល្បែង វិធានល្បែង ឧបករណ៍និង/ឬកម្មវិធីល្បែងដោយមិនមានការអនុញ្ញាតពី គ.ល.ក. ត្រូវផ្ដន្ទាទោសតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ២៣ .-**

ប្រតិបត្តិករកាស៊ីណូដែលប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌណាមួយ ដែលកំណត់ដោយប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មរដ្ឋបាល ដូចមានចែងក្នុងច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**ប្រការ២៤ .-**

ប្រតិបត្តិករកាស៊ីណូដែលបាននិងកំពុងដាក់ឱ្យដំណើរការនូវប្រភេទល្បែង វិធានល្បែង ឧបករណ៍ និង/ឬកម្មវិធីល្បែង មុនពេលមានប្រកាសនេះ ត្រូវមកបំពេញកាតព្វកិច្ចដូចមានចែងក្នុងប្រកាសនេះ ក្នុងរយៈពេលយ៉ាងយូរ ១២ (ដប់ពីរ) ខែ គិតចាប់ពីថ្ងៃចូលជាធរមាននៃប្រកាសនេះ។

ប្រតិបត្តិករកាស៊ីណូដែលមិនបានមកបំពេញកាតព្វកិច្ចតាមកាលកំណត់ខាងលើ ត្រូវចាត់ទុកថា ដំណើរការប្រភេទល្បែង វិធានល្បែង ឧបករណ៍និង/ឬកម្មវិធីល្បែងដោយមិនមានការអនុញ្ញាតពី គ.ល.ក.។

**ប្រការ២៥ ._**

ឧបករណ៍និង/ឬកម្មវិធីល្បែងដែលកំពុងដំណើរការ និងមិនទាន់ផុតអាយុកាលប្រើប្រាស់ អាចបន្តដាក់ដំណើរការបានរហូតដល់កាលបរិច្ឆេទផុតអាយុកាលនៃឧបករណ៍និង/ឬកម្មវិធីល្បែងនោះ។

ឧបករណ៍និង/ឬកម្មវិធីល្បែងដែលកំពុងដំណើរការ និងផុតអាយុកាលប្រើប្រាស់ មិនអាចបន្តដាក់ដំណើរការបានទេ គិតចាប់ពីថ្ងៃចូលជាធរមាននៃប្រកាសនេះ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ២៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២៧ ._**

អគ្គលេខាធិការ គ.ល.ក. អគ្គលេខាធិការរង គ.ល.ក. ប្រតិបត្តិករនិង/ឬកម្មសិទ្ធិករកាស៊ីណូ និង/ឬកម្មសិទ្ធិករមណ្ឌលល្បែងពាណិជ្ជកម្មសមាហរ័ណ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៥រោច ខែ បឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ៦ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការគ្រប់គ្រងល្បែងពាណិជ្ជកម្មកម្ពុជា**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់សមាសភាពនៃ គ.ល.ក.
- រដ្ឋបាលរាជធានី-ខេត្ត
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ